# ដំណើររបស់យើងឆ្ពោះទៅរកសុវត្ថិភាព និងសុខុមាលភាពគ្រួសារ

ដែលធ្វើការជាមួយសេវាកម្មគាំទ្រកុមារ និងគ្រួសារនានា

## 1. ការព្រួយបារម្ភត្រូវបានលើកឡើង

មាននរណាម្នាក់ព្រួយបារម្ភអំពីសុវត្ថិភាពគ្រួសារ និងកូនៗរបស់អ្នក។

## 2. ការបញ្ជូនបន្តត្រូវបានធ្វើឡើង

ការបញ្ជូនបន្តត្រូវបានធ្វើឡើងដើម្បីភ្ជាប់គ្រួសាររបស់អ្នក ទៅកាន់សេវាកម្មគាំទ្រត្រឹមត្រូវដើម្បីជួយរក្សាសុវត្ថិភាពកូនៗរបស់អ្នកនៅផ្ទះ។

## 3. ភ្ជាប់ទៅកាន់សេវាកម្មគាំទ្រកុមារ និងគ្រួសារ

សេវាកម្មគាំទ្រកុមារ និងគ្រួសារត្រូវបានរកឃើញដែលត្រូវសមនឹងតម្រូវការរបស់អ្នក។

## 4. ចាប់ផ្តើមធ្វើការជាមួយសេវាកម្មគាំទ្រកុមារ និងគ្រួសារ

យើងនឹងនិយាយជាមួយក្រុមគ្រួសាររបស់អ្នក – រួមទាំងកូនៗរបស់អ្នកផងដែរ – អំពីរបៀបដែលយើងអាចជួយសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ យើងនឹងស្តាប់រឿងរ៉ាវ ចំណុចខ្លាំង ការព្រួយបារម្ភ និងក្តីសង្ឃឹមរបស់គ្រួសារអ្នក។

## 5. ការធ្វើផែនការសុវត្ថិភាព

រួមគ្នា យើងនឹងរៀបចំផែនការសកម្មភាពនានាដែលត្រូវធ្វើឡើងឥឡូវនេះ ដើម្បីបង្កើនសុវត្ថិភាព និងសុខុមាលភាពកូនៗរបស់អ្នក។

## 6. ធ្វើការជាមួយគ្នា

យើងនឹងជួបប្រជុំជាប្រចាំជាមួយក្រុមគ្រួសាររបស់អ្នក – រួមទាំងកូនៗរបស់អ្នកផងដែរ – ដើម្បីបង្កើត និងធ្វើការលើគោលដៅគ្រួសាររបស់អ្នកដើម្បីធានាថាកូនៗ និងក្រុមគ្រួសាររបស់អ្នកមានសុវត្ថិភាព និងមានសុខភាពល្អ។ គោលដៅ និងសកម្មភាពគ្រួសាររបស់អ្នកអាចត្រូវបានធ្វើបច្ចុប្បន្នភាពខណៈពេលកំពុងដំណើរការ ឬនៅពេលមានតម្រូវការផ្លាស់ប្តូរ។

## 7. គោលដៅដែលបានបញ្ចប់

នៅចុងបញ្ចប់នៃពេលវេលាដែលយើងនៅជាមួយគ្នា យើងនឹងឆ្លុះបញ្ចាំងពីវឌ្ឍនភាពដែលគ្រួសាររបស់អ្នកសម្រេចបាន ហើយត្រូវប្រាកដថាគ្រួសាររបស់អ្នកមានទំនាក់ទំនងជាមួយសេវាកម្មមានប្រយោជន៍ផ្សេងទៀត ឬការគាំទ្រពីសហគមន៍នានា ដើម្បីរក្សាការផ្លាស់ប្តូរវិជ្ជមានទាំងនេះ។

2025 DHS-328

Government of South Australia
human services

KHMER